**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

**លេខ:** ០១៧៥ សហក.សគ.

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

ក្នុងគោលបំណង ដើម្បីបង្វិតសេវាឲ្យទៅជិតប្រជាពលរដ្ឋ បង្កភាពងាយស្រួល ចំណេញពេលវេលា និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្រសួងសាធារណការ និងដឹកជញ្ជូន មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា៖ ក្រសួងបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរយានយន្ត នៅ**ជាន់ទីមួយ ផ្សារទំនើប AEON Mall** មានអាសយដ្ឋានស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦** តទៅ។ មណ្ឌលនេះអនុញ្ញាតឲ្យប្រជាជនខ្មែរ ទាំង២៥រាជធានី-ខេត្ត អាចមកទទួលសេវា ជារៀងរាល់ថ្ងៃ ចាប់ពី**ម៉ោង០៨ព្រឹក រហូតដល់ ម៉ោង១០យប់**។

បានទទួលសេចក្តីជំណឹងនេះ សូមសាធារណជនទាំងអស់ ដែលមានបណ្ណបើកបរយានយន្តអស់សុពលភាព ខូច ឬបាត់បង់ដោយប្រការណាមួយ អាចអញ្ជើញទៅកាន់មណ្ឌលប្តូរ និងពន្យារបណ្ណបើកបរយានយន្ត នៅផ្សារទំនើប AEON Mall ចាប់ពីការបរិច្ឆេទដាក់ឲ្យដំណើរការជាផ្លូវការខាងលើនេះតទៅ។

**សូមអរគុណ**